# របាយការណ៍ស្តីពីការវាយតម្លៃបឋម

## ប្រកាសស្តីពីការហ្វឹកហ្វឺនកូនជាង ឆ្នាំ២០០០

## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខយោង: 0000019

កាលបរិច្ឆេទចាប់ផ្តើម: ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤

កាលបរិច្ឆេទបញ្ចប់ : ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៤

ទំនាក់ទំនង:

| ក្រុម | នាមនិងគោត្តនាម | តួនាទី | លេខទូរស័ព្ទ | អ៊ីម៉ែល |
|---|---|---|---|---|
| RIA | ឯ.ឧ ហេង សួរ | ប្រធាន RIA | 012-693-777 | hengsour@yahoo.com |
| | លោក តឹប អឿន | អនុប្រធាន RIA | 012-606-572 | tepoeuntvet@gmail.com |
| | លោក ទី សេរីរិទ្ធ | សមាជិក RIA | 012-851-884 | sereirith_ty@yahoo.com |
| | លោក លេង ប៊ុនណារ៉ា | សមាជិក RIA | 089-396-989 | tabunnara@yahoo.com |
| | លោក ធាង ស៊ាងវេង | Supporting staff | 077-889-954 | seangveng_theang@yahoo.com |
| ORIA | លោក សំ សំណាង | ORIA-ទទួលបន្ទុក | 077-644-095 | somnangs001@gmail.com |
| | លោក ហេង សុភៈបញ្ញា | ORIA-ជំនួស | 016-847-749 | pangha.h@gmail.com |

### អត្ថាធិប្បាយសង្ខេបអំពីសំណើបញ្ញត្តិកម្ម

ប្រកាសនេះ (យោងតាមមាត្រា១ និងជំពូកទី៣ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧) តម្រូវឲ្យសហគ្រាស គ្រឹះស្ថាន រោងចក្រទាំងឡាយដែលប្រើប្រាស់កម្មករ និយោជិកច្រើនជាង៦០នាក់ ត្រូវអនុវត្តនូវការហ្វឹកហ្វឺនកូនជាង[1]។ ចំពោះសហគ្រាស គ្រឹះស្ថាន រោងចក្រដែលបើកថ្មីត្រូវអនុវត្តការហ្វឹកហ្វឺនកូនជាងយ៉ាងយូរបំផុតនៅ៣ខែក្រោយចាប់ផ្តើមដំណើរការជាផ្លូវការ។ ចំពោះសហគ្រាស គ្រឹះស្ថាន រោងចក្រទាំងឡាយណាដែលគ្មានលទ្ធភាពហ្វឹកហ្វឺនកូនជាងត្រូវធ្វើសំណើមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីធ្វើការសុំបង់ពន្ធអាករហ្វឹកហ្វឺនកូនជាងជំនួសវិញ (១%លើប្រាក់ឈ្នួលប្រចាំឆ្នាំនៃចំនួនសរុបរបស់កម្មករនិយោជិតទាំងអស់របស់សហគ្រាសជារៀងរាល់ឆ្នាំ)។ ប្រកាសនេះមានគោលបំណងបង្កើនចំណេះដឹង ចំណេះធ្វើ កែលម្អឥរិយាបទការងារដល់កម្មករនិយោជិតដើម្បីទទួលបានការងារពេញមួយជីវិត និងសំដៅលើកកម្ពស់ផលិតភាពរបស់កម្មករនិយោជិតនៃសហគ្រាស គ្រឹះស្ថាន រោងចក្រ។

[1] *កូនជាងគឺជាជនដែលបានចុះកិច្ចសន្យាសិក្សាវិជ្ជាជីវៈជាមួយនឹងនិយោជកឬសិប្បករណាម្នាក់ ដែលបានចុះកិច្ចសន្យានឹងគ្នាថា និយោជកត្រូវបង្រៀន ឬប្រើគេឲ្យបង្រៀនវិជ្ជាជីវៈខ្លួនហើយកូនជាងត្រូវធ្វើការឲ្យនិយោជកតែតាមលក្ខខ័ណ្ឌនិងក្នុងរយៈពេលនៃកិច្ចសន្យា (មាត្រា៨ នៃច្បាប់ស្តីពីការងារ)។*

ប្រភេទបញ្ញត្តិកម្ម

| ច្បាប់ | ព្រះរាជក្រឹត្យ | អនុក្រឹត្យ | ប្រកាស | សេចក្តីសម្រេច | សារាចរ | ផ្សេងទៀត |
|---|---|---|---|---|---|---|
| ☐ | ☐ | ☐ | ☑ | ☐ | ☐ | ☐ |

តើសំណើនេះមានចរិកជាបញ្ញត្តិកម្ម ហើយវាមានផលប៉ះពាល់ដល់ធុរកិច្ចដែរឬទេ?
*(ចរិកជាបញ្ញត្តិកម្មមានន័យថាសំណើនឹងធ្វើឲ្យមានការផ្លាស់ប្តូរឥរិយាបទ)*
☑មែន/ ☐មិនមែន

**១. ការកំណត់បញ្ហា** *(ដែលក្រសួង ស្ថាប័នមានបំណងដោះស្រាយដោយបញ្ញត្តិកម្មនេះ)*

| បញ្ហាសំខាន់ៗ | បញ្ញត្តិកម្មនេះមានបំណងដោះស្រាយ *(គូស✓ មែនឬមិនមែន)* | ភស្តុតាង/ភាពជាក់ស្តែង (សូមភ្ជាប់កំណត់សម្គាល់ប្រសិនបើចាំបាច់) |
|---|---|---|
| សុខភាពនិងសុវត្ថិភាពសាធារណៈ | មិនមែន | |
| ការការពារនិងអភិរក្សបរិស្ថាន | មិនមែន | |
| សមធម៌យេនឌ័រនិងសង្គម និងការអភិរក្សវប្បធម៌ | មានការទាក់ទង | ក្នុងចំណោមកម្មករនិយោជិតវិស័យវាយនភ័ណ្ឌ មាន៧៩%ជាស្ត្រី។ ប្រកាសនេះជួយបង្កើនសម្ថភាព ជំនាញ និងប្រាក់ចំណូលស្ត្រី។ |
| ការប្រកួតប្រជែង | មានការទាក់ទង | ការលើកកម្ពស់ជំនាញ ពង្រឹងការបណ្តុះបណ្តាល និងហ្វឹកហ្វឺនកូនជាង គឺជាការបង្កើនផលិតភាពពលកម្ម ដែលនេះជាបរិបទជំរុញភាពប្រកួតប្រជែងជាតិ (Berik & Rodgers, 2010; Salinger et al., 2005)។ |
| ការប្រមូលព័ត៌មាន | មិនមែន | |
| អនុលោមតាមកិច្ចព្រមព្រៀង WTO និងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត | មិនមែន | |

*ប្រសិនបើមានបញ្ហាផ្សេងទៀតសូមអធិប្បាយនិងផ្តល់ភស្តុតាង*

- សមត្ថភាពជំនាញរបស់កម្មករនិយោជិតនៅមានកម្រិត
- ផលិតភាពកម្មករនិយោជិត និងប្រាក់កម្រៃពលកម្មនៅមានកម្រិតទាប បើធៀបទៅនឹងបណ្តាប្រទេសដទៃទៀត ដូចជា ប្រទេសវៀតណាម និងចិន (Berik & Rodgers, 2010)
- គ្រោះថ្នាក់ការងារតែងតែកើតមានឡើងដោយសារការហ្វឹកហ្វឺនកូនជាងមិនទាន់បានពេញលេញ

សូមរាយបញ្ជីលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ដែលពាក់ព័ន្ធឬប្រហាក់ប្រហែល។

១. ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧
២. យោងតាមច្បាប់វិនិយោគ មាត្រា១៨ថ្មី ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣
៣. ប្រកាសស្តីពីការហ្វឹកហ្វឺនវិជ្ជាជីវៈដល់ក្មេងសិក្សាប់ធ្វើការក្រោមដី លេខ១៤៥ សបកយ ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០០២

ចូរបញ្ជាក់ថាតើហេតុអ្វីបានជាលិខិតបទដ្ឋានគតិយុត្តទាំងនេះមិនទាន់គ្រប់គ្រាន់?

លិខិតបទដ្ឋានគតិយុត្តខាងលើមានលក្ខណៈទូទៅពេក មិនបានកំណត់គោលការណ៍ជាក់លាក់ ដូចជា ចំនួនភាគរយនៃកម្មករនិយោជិតដែលត្រូវទទួលបានការហ្វឹកហ្វឺន អត្រាបង់ពន្ធអាករសម្រាប់ការហ្វឹកហ្វឺនកូនជាង និងនីតិវិធីពាក់ពន្ធនឹងការហ្វឹកហ្វឺនកូនជាង ...។

តើយើងពិតជាចាំបាច់ត្រូវរកជម្រើសផ្សេងទៀតដែរឬទេ? ☑មែន

## ២. គោលបំណង - តើយើងចង់សម្រេចបានអ្វី?

- បង្កើនសមត្ថភាពជំនាញនិងទទួលបានការងារពេញមួយជីវិតរបស់កម្មករនិយោជិត
- លើកកម្ពស់ផលិតភាព និងប្រាក់កម្រៃពលកម្មកម្មករនិយោជិត
- កាត់បន្ថយគ្រោះថ្នាក់ការងារ និងបង្កើនលក្ខខណ្ឌការងារល្អប្រសើរដល់កម្មករនិយោជិត។

## ៣. ជម្រើស - ពិចារណាជម្រើសផ្សេងៗ

ជម្រើសផ្សេងៗដែលអាចអនុវត្តបាន (សម្រាប់ការវិភាគលើផលប៉ះពាល់)

១. ប្រកាសស្តីពីការហ្វឹកហ្វឺនកូនជាង (សហគ្រាស គ្រឹះស្ថាន រោងចក្រទាំងឡាយណាដែលគ្មានលទ្ធភាព និងរៀបចំការហ្វឹកហ្វឺនកូនជាងបានត្រូវធ្វើសំណើមកក្រសួង ដើម្បីធ្វើការសុំបង់ពន្ធអាករសម្រាប់ការហ្វឹកហ្វឺនកូនជាងជំនួសវិញ)
២. ប្រកាសស្តីពីការបង់ពន្ធអាករសម្រាប់ការហ្វឹកហ្វឺនកូនជាង (តម្រូវឲ្យគ្រប់សហគ្រាស គ្រឹះស្ថាន រោងចក្រ បង់ពន្ធអាករសម្រាប់ការហ្វឹកហ្វឺនកូនជាងជូនទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)

## ៤. ការប៉ាន់ស្មានបឋមលើចំណាយភាគពួកិច្ចនិងផលប៉ះពាល់ដល់ការប្រកួតប្រជែង

### ៤.១. ការកំណត់ភារកិច្ច និងប្រភេទចំណាយ(tasks and cost-categories)

*គោលការណ៍ណែនាំបានផ្តល់តារាងនៃប្រភេទចំណាយដែលអាចមាន*

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| ជម្រើសទី១: | - បន្ទុកចំណាយលើដំណើរការតាក់តែងប្រកាស<br>- បន្ទុកចំណាយលើការពិគ្រោះយោបល់<br>- បន្ទុកចំណាយលើការរក្សាទុកឯកសារ<br>- បន្ទុកចំណាយលើការបោះពុម្ព និងផ្សព្វផ្សាយ<br>- បន្ទុកចំណាយលើការពង្រឹងការអនុវត្ត<br>- បន្ទុកចំណាយផ្សេងៗ | - បន្ទុកចំណាយលើការហ្វឹកហ្វឺនកូនជាង (ប្រាក់ឧបត្ថម្ភគ្រូ/ជំនាញការកូនជាង)<br>- បន្ទុកចំណាយលើការទិញឧបករណ៍សម្ភារៈផ្សេងៗ<br>- ឬបន្ទុកចំណាយលើការបង់ពន្ធ១%ជូនក្រសួង<br>- បន្ទុកចំណាយលើបដិសណ្ឋារកិច្ច |
| ជម្រើសទី២: | - បន្ទុកចំណាយលើដំណើរការតាក់តែងប្រកាស<br>- បន្ទុកចំណាយលើការពិគ្រោះយោបល់<br>- បន្ទុកចំណាយលើការហ្វឹកហ្វឺនកូនជាង (ប្រាក់ឧបត្ថម្ភគ្រូ/ជំនាញការ កូនជាង)<br>- បន្ទុកចំណាយលើការរក្សាទុកឯកសារ<br>- បន្ទុកចំណាយលើការបោះពុម្ព និងផ្សព្វផ្សាយ<br>- បន្ទុកចំណាយលើការពង្រឹងការអនុវត្ត<br>- បន្ទុកចំណាយផ្សេងៗ | - បន្ទុកចំណាយលើការបង់ពន្ធ១%ជូនក្រសួង<br>- បន្ទុកចំណាយលើប្រាក់ខែកូនជាង<br>- បន្ទុកចំណាយលើបដិសណ្ឋារកិច្ច |

### ៤.២. វិសាលភាពនៃជម្រើសនីមួយៗ

| ជម្រើស | វិស័យឬប្រភេទធុរកិច្ច | ចំនួនធុរកិច្ច | ឯកសារយោង/ភស្តុតាង |
|---|---|---|---|
| ជម្រើសទី១: ប្រកាស | ឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សិប្បកម្ម សេវាកសិកម្ម ដឹកជញ្ជូន... (យោងមាត្រា១នៃច្បាប់ស្តីពីការងារ) | ១៦០០ | ជំរឿនសហគ្រាស២០១១ (NIS/MOP) |

| | | | |
|---|---|---|---|
| ជម្រើសទី២: ប្រកាស | ឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សិប្បកម្ម សេវា កសិកម្ម ដឹកជញ្ជូន... (យោងមាត្រា១នៃច្បាប់ស្តីពីការងារ) | ១៦០០ | ជំរឿនសហគ្រាស២០១១ (NIS/MOP) |

៤.៣. ប៉ាន់ស្មានចំណាយបន្ថែមរបស់ធុរកិច្ចនិងរាជរដ្ឋាភិបាល

| ធុរកិច្ច | | |
|---|---|---|
| ជម្រើស | កំណើនចំណាយអនុលោមតាមបញ្ញត្តិកម្ម | ផ្តល់អំណះអំណាង |
| ជម្រើសទី១: ប្រកាស | មិនគួរឲ្យកត់សម្គាល់ | បន្ទុកចំណាយសរុបចំនួន ១១ ៥២៥ ៥០០ដុល្លារគ្របណ្តប់ទៅលើធុរកិច្ច ១៦០០ (ធុរកិច្ចមួយចំណាយអស់ ៧ ២០៣ ដុល្លារ)។ បន្ទុកចំណាយនេះមិនគួរឲ្យកត់សម្គាល់នោះទេ បើប្រៀបធៀបនឹងចំណូលរបស់ធុរកិច្ចប្រចាំឆ្នាំ (ឧទាហរណ៍: ចំណូលមធ្យមរបស់រោងចក្រកាត់នៅកម្ពុជាក្នុងឆ្នាំ២០០៨ ស្មើនឹង ១១ លានដុល្លា (Asuyama, Chhun, Fukunishi, Neou, & Yamagata, 2013)។ |
| ជម្រើសទី២: ប្រកាស | មិនគួរឲ្យកត់សម្គាល់ | បន្ទុកចំណាយសរុបចំនួន ១២ ៤៧២ ០០០ដុល្លារគ្របដណ្តប់ទៅលើធុរកិច្ច ១៦០០ (ធុរកិច្ចមួយចំណាយអស់ ៧ ៧៩៥ ដុល្លារ)។ បន្ទុកចំណាយនេះមិនគួរឲ្យកត់សម្គាល់នោះទេ បើប្រៀបធៀបនឹងចំណូលរបស់ធុរកិច្ចប្រចាំឆ្នាំដូចគ្នាក្នុងឧទាហរណ៍ខាងលើ។ |

| រាជរដ្ឋាភិបាល | | |
|---|---|---|
| ជម្រើស | កំណើនចំណាយ អនុលោមតាមបញ្ញត្តិកម្ម | ផ្តល់អំណះអំណាង |
| ជម្រើសទី១ : ប្រកាស | មិនគួរឲ្យកត់សម្គាល់ | បន្ទុកចំណាយសរុបចំនួន ១៧៦ ៥៩១ ដុល្លារ គឺស្មើនឹង ០.៧% បើធៀបនឹងថវិកាប្រចាំឆ្នាំ២០១៣របស់ក្រសួង(២៧ លានដុល្លារ)។ |
| ជម្រើសទី២ :ប្រកាស | មិនគួរឲ្យកត់សម្គាល់ | បន្ទុកចំណាយសរុបចំនួន ៦ ១៦១ ៥៩៨ ដុល្លារ ប៉ុន្តែចំណូលដែលទទួលបានពីពន្ធអាករហ្វឹកហ្វឺនកូនជាងមានចំនួនរហូតដល់ ៧.៥៤ លានដុល្លារ។ ដូច្នេះបន្ទុកចំណាយនេះមិនគួរឲ្យកត់សម្គាល់នោះទេ។ |

៥.៤. ប៉ាន់ស្មានកម្រិតនៃផលចំណេញ

| ជម្រើស | ផលចំណេញ | ផ្តល់អំណះអំណាង |
|---|---|---|
| ជម្រើសទី១: ប្រកាស | គួរឲ្យកត់សម្គាល់ | - បង្កើនសមត្ថភាពជំនាញនិងទទួលបានការងារពេញមួយជីវិតរបស់កម្មករនិយោជិត<br>- លើកកម្ពស់ផលិតភាព និងប្រាក់កម្រៃពលកម្មកម្មករនិយោជិត<br>- កាត់បន្ថយគ្រោះថ្នាក់ការងារ និងបង្កើនលក្ខខណ្ឌការងារល្អប្រសើរដល់កម្មករនិយោជិត<br>- លើកកម្ពស់ភាពប្រកួតប្រជែងរបស់ឧស្សាហកម្មកម្ពុជាក្នុងឆាកអន្តរជាតិ។ |
| ជម្រើសទី២: ប្រកាស | គួរឲ្យកត់សម្គាល់ | អំណះអំណាងសម្រាប់ជម្រើសទី២នេះគឺដូចនឹងជម្រើសទីមួយ។ |

៥.៥. តើសំណើបញ្ញត្តិកម្មមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងដែរឬទេ?

☑មិនគួរឲ្យកត់សម្គាល់

*(ប្រសិនបើផលប៉ះពាល់ដល់ការប្រកួតប្រជែងគួរឲ្យកត់សម្គាល់ តម្រូវឲ្យធ្វើRIS)។*

| |
|---|
| បន្ទុកចំណាយរបស់ធុរកិច្ចក្នុងការអនុវត្តប្រកាសនេះមានចំនួនតិចតួចបើប្រៀបធៀបនឹងចំណូលប្រចាំឆ្នាំ ហើយក៏មិនមានផលប៉ះពាល់ដល់ការប្រកួតប្រជែងដែរ ។ |

៤.៦.តើសំណើបញ្ញត្តិកម្មនេះមានផលប៉ះពាល់អវិជ្ជមានលើសមធម៌យេនឌ័រដែរឬទេ?

*(តើបញ្ញត្តិកម្មនេះមានឥទ្ធិពលមកលើស្ត្រី (ជាបុគ្គលម្នាក់ៗ ឬធុរជនជាស្ត្រី) ច្រើនជាងបុរស ដែរឬទេ?)*

☑គួរឲ្យកត់សម្គាល់

| |
|---|
| យោងតាមរបាយការណ៍ក្នុងសៀវភៅផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨ ក្នុងចំណោមកម្មករធ្វើការក្នុងវិស័យវាយនភណ្ឌសរុប ៦២៨ ១៦៦ នាក់ មានស្ត្រីចំនួន ៤៦៣ ១៦១ នាក់ គឺស្មើនិង៧៤%។ ដូច្នេះបញ្ញត្តិកម្មនេះបានលើកកម្ពស់សមត្ថភាពជំនាញ និងបង្កើនប្រាក់ចំណូលរបស់ស្ត្រី។ |

## ៥. កិច្ចពិគ្រោះយោបល់

| ក្រុមអ្នកពាក់ព័ន្ធ | | វិធីសាស្ត្រ | សង្ខេបទស្សនៈ |
|---|---|---|---|
| ធុរកិច្ច | GMAC តំណាងឲ្យរោងចក្រកាត់ដេរចំនួន៩៥% | ទូរស័ព្ទ | - ជម្រើសទី១: គាំទ្រទៅលើកម្មវិធីហ្វឹកហ្វឺនកូនជាង<br>- ជម្រើសទី២: មិនយល់ស្របទៅលើការបង់ពន្ធអាករហ្វឹកហ្វឺន ១% លើប្រាក់ឈ្នួលប្រចាំឆ្នាំនៃកម្មករសរុប |
| | សហគ្រាស | N/A | N/A |
| អ្នកប្រើប្រាស់ | ក្រុមអ្នកប្រើប្រាស់ | N/A | N/A |
| រាជរដ្ឋាភិបាល | ក្រសួង/ស្ថាប័ន | N/A | N/A |
| យេនឌ័រ | ក្រុមស្ត្រី | N/A | N/A |
| អ្នកជំនាញ | ឈ្មោះ | N/A | N/A |
| ផ្សេងៗ | ឈ្មោះ | N/A | N/A |

## ៦.សន្និដ្ឋាន

៦.១. សេចក្តីសង្ខេបនៃចំណាយកាតព្វកិច្ចបន្ថែមនិងផលចំណេញ

| ជម្រើស | ចំណាយរបស់ធុរកិច្ច | ចំណាយរបស់រាជរដ្ឋាភិបាល | ផលចំណេញ |
|---|---|---|---|
| ជម្រើសទី១: ប្រកាស | មិនគួរឲ្យកត់សម្គាល់ | មិនគួរឲ្យកត់សម្គាល់ | គួរឲ្យកត់សម្គាល់ |

| ជម្រើសទី២: ប្រកាស | មិនគួរឲ្យកត់សម្គាល់ | មិនគួរឲ្យកត់សម្គាល់ | គួរឲ្យកត់សម្គាល់ |
|---|---|---|---|

**៦.២. តើចាំបាច់ធ្វើRIS ដែរឬទេ?**

☑មិនចាំបាច់- *សូមផ្តល់អំណះអំណាងនិងបំពេញការវាយតម្លៃបឋម(PA) ដែលនៅសេសសល់។*

| |
|---|
| សំណើបញ្ញត្តិកម្មនេះមិនមានបន្ទុកចំណាយធ្ងន់ធ្ងរដល់ធុរកិច្ចទេ។ |

**៦.៣. ជម្រើសដែលបានជ្រើសរើស** (*សូមអធិប្បាយអំពីជម្រើសនិងសូមបញ្ជាក់ថាតើជម្រើសនេះនឹងធ្វើឲ្យស្ថានភាពប្រសើរឡើងយ៉ាងដូចម្តេច*)

| |
|---|
| ជម្រើសទី១ ជាជម្រើសដែលគួរទទួលយកពីព្រោះយោងតាមលទ្ធផលនៃការពិគ្រោះយោបល់សង្គមធុរកិច្ចបានគាំទ្រជម្រើសនេះ( GMAC ដែលជាសមាគមតំណាងឲ្យរោងចក្រកាត់ដេរចំនួន ៩៥% នៅកម្ពុជា)។ |

| លក្ខណវិនិច្ឆ័យ | | មូលហេតុ |
|---|---|---|
| តើវាជាជម្រើសដែលមានចំណាយកាតព្វកិច្ចបន្ថែមអប្បបរមាសម្រាប់វិស័យធុរកិច្ចនិងសហគមន៍ដែរឬទេ? | មែន | ធុរកិច្ចនីមួយៗត្រូវចំណាយបន្ថែម ៧២០៣ដុល្លារក្នុងមួយឆ្នាំទៅលើការហ្វឹកហ្វឺកកូនជាង។ បន្ទុកចំណាយនេះមិនគួរឲ្យកត់សម្គាល់នោះទេ បើប្រៀបធៀបនឹងចំណូលរបស់ធុរកិច្ចប្រចាំឆ្នាំ (ឧទាហរណ៍ ចំណូលមធ្យមរបស់រោងចក្រកាត់ដេរនៅកម្ពុជាក្នុងឆ្នាំ២០០៨ ស្មើនឹង ១១ លានដុល្លា (Asuyama, Chhun, Fukunishi, Neou, & Yamagata, 2013)។ |
| តើជម្រើសនេះផ្តល់នូវផលចំណេញអតិបរមាដែរឬទេ? | មែន | - មានផលចំណេញចំពោះកម្មករនិយោជិត ក្នុងន័យការបង្កើនជំនាញ និងប្រាក់កម្រៃពលកម្ម<br>- មានផលចំណេញចំពោះធុរកិច្ចក្នុងន័យការកើនឡើងនៃផលិតភាពពលកម្ម<br>- ភាពប្រកួតប្រជែងនៃឧស្សាហកម្មជាតិទាំងមូលមានការកើនឡើង។ |

## ៧. ការអនុវត្តនិងការតាមដាន

ប្រសិនបើជម្រើសបញ្ញត្តិកម្មត្រូវបានជ្រើសរើស៖

៧.១.តើវិធានការអ្វីត្រូវបានជ្រើសរើសដើម្បីលើកកម្ពស់តម្លាភាពនិងអភិបាលកិច្ចល្អក្នុងអំឡុងពេលនៃការប្រតិបត្តិ?

| |
|---|
| ក្រសួងចុះធ្វើអធិការកិច្ចការហ្វឹកហ្វឺនកូនជាង នៅតាមបណ្តាសហគ្រាស គ្រឹះស្ថាន រោងចក្រដែលមានកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង២ដងក្នុង១ឆ្នាំ។ |

៧.២.តើគួរធ្វើការពិនិត្យ/តាមដានបញ្ញត្តិកម្មនេះឡើងវិញក្រោយពេលបញ្ញត្តិកម្មនេះត្រូវបានប្រតិបត្តិដែរឬទេ?បើដូច្នោះតើបញ្ញត្តិកម្មនេះគួរត្រូវបានពិនិត្យឡើងវិញ/តានដានយ៉ាងដូចម្តេច និងនៅពេលណា?

| |
|---|
| បញ្ញត្តិកម្មនេះត្រូវបានពិនិត្យឡើងវិញក្នុងរយៈពេល៣ឆ្នាំ ដោយផ្អែកលើការវិវឌ្ឍតាមវិស័យ និងស្ថានភាពសេដ្ឋកិច្ច។ |

## អត្ថាធិប្បាយផ្សេងទៀត

| |
|---|
| - ការអនុវត្តកម្មវិធីហ្វឹកហ្វឺនមិនទាន់កំណត់ឲ្យបានច្បាស់លាស់នូវស្តង់ដារួមមួយសម្រាប់ឲ្យសហគ្រាសគ្រឹះស្ថានរោងចក្រនីមួយៗប្រើប្រាស់ជាទូទៅ (ប្រការ៦)។<br>- ឈ្មោះក្រសួងដែលទទួលខុសត្រូវសព្វថ្ងៃខុសពីខ្លឹមសារដែលមានចែងក្នុងប្រកាសនេះ (ប្រការ៦ និងប្រការ៨)។<br>- បេឡាបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានចែងក្នុងប្រកាសនេះ រហូតមកដល់ពេលនេះមិនទាន់បានបង្កើតនៅឡើយ (ប្រការ៨)។<br>- សមត្ថភាពរបស់កម្មករនិយោជិតគឺមិនទាន់បានឆ្លើយតបទៅនឹងការវិវឌ្ឍរបស់បច្ចេកវិទ្យា និងសង្គម-សេដ្ឋកិច្ច ជាពិសេសពេលដែលធ្វើសមាហរកម្មកម្លាំងពលកម្មទៅក្នុងតំបន់អាស៊ាន ២០១៥ (ការបន្លាស់ទីរូបវន្តបុគ្គល) និងអន្តរជាតិ។ |

| ដំណើរការ | ឈ្មោះ | មុខងារ | ហត្ថលេខា | កាលបរិច្ឆេទ |
|---|---|---|---|---|
| រៀបចំដោយ (ក្រសួងពាក់ព័ន្ធ) | ឯ.ឧ ហេង សួរ | ប្រធាន RIA/MLVT | | 26/3/2014 |
| ត្រួតពិនិត្យដោយ (ORIA) | លោក សំ សំណាង | សមាជិក RIA | | 27/03/2014 |
| | ឯ.ឧ អេង រត្នមុនី | ប្រធានផ្នែក RIA | | 27/3/2014 |
| | ឯ.ឧ ម៉ម សារិទ្ធ | ប្រធានផ្នែក CBA | | 27/3/2014 |
| ឯកភាពដោយ (ORIA) | ឯ.ឧ ប៉ិច សុខា | ប្រធានគម្រោង | | 27/3/2014 |
| បញ្ចូលទិន្នន័យដោយ | លោក លេង ប៊ុនណារ៉ា | សមាជិក RIA/MLVT | | 27/3/2014 |
| បញ្ចូលក្នុងគេហទំព័រដោយ | [illegible] | សមាជិក I.Center | | 28/3/2014 |